ភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែឧសភា ឆ្នាំ២០១៦



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធ ប្រចាំខែឧសភា ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួមពី ឯកឧត្តម-លោកស្រីអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋានលោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានសំដែងអំណរសាទរ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារដែលសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០១៦ ព្រមទាំងជំរុញការលើកទឹកចិត្ត ថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ និងមន្ត្រីពន្ធដារទូទាំងប្រទេស ដែលបានខិតខំជំនះរាល់ការលំបាក និងបញ្ហាប្រឈមនានា ក្នុងការខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ដែលសម្រេចបានតាមគោលដៅកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានា សំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៦។

ក្នុងខែឧសភាឆ្នាំ២០១៦នេះអគ្គនាយកដ្ឋានពន្ធដារប្រមូល



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ចំណូលពន្ធ-អាករគ្រប់ប្រភេទ បានចំនួន ៤៨៥ ៩៧៤,២៨ លានរៀល (គិតជាដុល្លារប្រមាណ ១២១,៤៩ លានដុល្លារ)។ សម្រាប់រយៈពេល ០៥ខែ ឆ្នាំ២០១៦ ចំណូលពន្ធ-អាករសរុបដែលអគ្គនាយកដ្ឋានពន្ធដារ ប្រមូលបាន មានចំនួន ២ ៨៣៣ ០៥៩,៤៣ លានរៀល (គិតជាដុល្លារប្រមាណ ៧០៨,២៦ លានដុល្លារ) ស្មើនឹង ៤៩,៨២% នៃគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៦។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០១៥ ឃើញថា ការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ សម្រាប់រយៈពេល ០៥ ខែ ឆ្នាំ២០១៦ មានការកើនឡើងចំនួន ៣៩២ ៣០៨,១៣ លានរៀល (ប្រមាណជា ៩៨,០៨ លានដុល្លារ) ឬស្មើនឹងអត្រាកំណើន ២១,៦៨%។

ក្នុងរយៈពេលដូចគ្នានេះដែរ ឃើញថា ក៏មានការកើនឡើងផងដែរ នូវចំណូលពន្ធ-អាករតាមប្រភេទពន្ធ សំខាន់ៗមួយចំនួន ដូចជា ពន្ធលើប្រាក់ចំណេញ ២១,៦% ពន្ធលើប្រាក់បៀវត្សកើនឡើងប្រមាណ៣២,១%អាករលើតម្លៃបន្ថែមកើនឡើងប្រមាណ ១០,៩% និងអាករពិសេសកើនឡើងប្រមាណ ២០,២%។ ម្យ៉ាងទៀត ចំណូលពន្ធតាមសកម្មភាពអាជីវកម្ម ក៏មានការកើនឡើងស្ទើរតែទាំងអស់ដែរ។

ក្នុងការពិភាក្សាគ្នា អង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ១)ពិនិត្យនិងពិភាក្សាលើរបាយការណ៍ចំណូលពន្ធប្រចាំខែឧសភា ឆ្នាំ២០១៦ របស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ។ ២) ពិនិត្យពិភាក្សា មានដូចជា ពង្រឹងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពសហគ្រាស ពង្រឹងការចាត់ចែងលិខិតប្រកាស ពង្រឹងការធ្វើសវនកម្មពន្ធ ពង្រឹងការគ្រប់គ្រងប្រមូលបំណុលពន្ធ (ការធ្វើបច្ចុប្បន្នភាពសហគ្រាសនៅជំពាក់បំណុលពន្ធ ការអនុវត្តវិធានការតឹងទារបំណុលពន្ធ) និងការដោះស្រាយវិវាទ ពង្រឹងការត្រួតពិនិត្យអង្កេត និងផ្តុំព័ត៌មានអ្នកជាប់ពន្ធ។ ៣) ពិភាក្សាការប្រមូលចំណូលពន្ធលើប្រភេទពន្ធមួយចំនួនមានដូចជា ពន្ធសត្តឃាត ការត្រួតពិនិត្យពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៥ អាករលើតម្លៃបន្ថែម ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពង្រឹងប្រព័ន្ធគ្រប់គ្រង ផ្នែកបច្ចេកវិទ្យាព័ត៌មាននៅតាមសាខាពន្ធដារខេត្ត-ខណ្ឌនីមួយៗ។ ៤) ពិភាក្សាអំពីកិច្ចការនៃការចុះអង្កេតស្រាវជ្រាវសហគ្រាស តាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារ បានគ្រប់ៗគ្នា។ ៥) ត្រៀមលក្ខណៈសម្រាប់ការគ្រប់គ្រងប្រមូលចំណូលពន្ធលើអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦។ ៦ ) របាយការណ៍លទ្ធផលស្តីពីការត្រួតពិនិត្យការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ឆ្នាំ២០១៥។ ៧)វឌ្ឍនភាពការងារកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ រួមមានការកែទម្រង់រដ្ឋបាលសារពើពន្ធ និងការកែទម្រង់គោលនយោបាយនិងនីតិកម្មសារពើពន្ធ។ ៨) បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលពន្ធ បានគ្រប់តាមផែនការច្បាប់ សម្រាប់ឆ្នាំ២០១៦ ក៏ដូចជាសម្រាប់បណ្ដាឆ្នាំបន្តបន្ទាប់ខាងមុខ អគ្គនាយកដ្ឋានពន្ធដារ នឹងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយកែទម្រង់ដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល និងបានដាក់ចេញនូវវិធានការ និងទិសដៅអនុវត្តបន្ត ដូចខាងក្រោម៖

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។
- បន្តពិនិត្យកែសម្រួលឡើងវិញ នូវច្បាប់ស្តីពីសារពើពន្ធ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពវិវឌ្ឍន៍នៃសង្គមជាតិ។
- បន្តពង្រឹងការប្រមូលពន្ធលើការជួលអចលនទ្រព្យ (ដី-ផ្ទះ) តាមរយៈការដាក់ឲ្យអនុវត្ត ការគ្រប់គ្រងការប្រកាសបង់ពន្ធប្រភេទនេះ តាមប្រព័ន្ធកុំព្យូទ័រថ្មី។
- បន្តយកចិត្តទុកដាក់ និងពង្រឹងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស។
- បន្តពង្រឹងការធ្វើសវនកម្ម ចំពោះវិស័យសំខាន់ៗមួយចំនួនដែលមានសក្តានុពលចំណូលពន្ធខ្ពស់ ជាអាទិ៍ វិស័យទេសចរណ៍ (ផ្នែកសណ្ឋាគារ-ផ្ទះសំណាក់) វិស័យនាំចេញ-នាំចូល វិស័យសំណង់ជាដើម។
- បន្តនីតិវិធីនៃការចុះអង្កេត ស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារបានគ្រប់ៗគ្នា។



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

- រៀបចំនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីដាក់ឲ្យអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៦។
- បន្តយកចិត្តទុកដាក់ តាមដានទំព័របណ្តាញសង្គមរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ដើម្បីឆ្លើយតបទៅនឹងចម្ងល់ដែលលើកឡើងដោយអ្នកជាប់ពន្ធ ឲ្យបានទាន់ពេលវេលា។
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Data Base) ដែលមានលក្ខណៈល្អប្រសើរ ដើម្បីងាយស្រួល ក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធ។

ជាកិច្ចបញ្ចប់ ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូល មានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែម ប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ គោរពវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធ ប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់ និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធ ដើម្បីការប្រមូលពន្ធ ឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបាន តាមផែនការក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦៕